Seattle Department of Transportation

# ស្ពានទាបស៊ីអាថូខាងលិចការផាកពិន័យតាមរូបថតនិងត្រូវបានអនុវត្តនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ដើម្បីផ្តល់អទិភាពដល់ រថយន្តសង្គ្រោះបន្ទាន់ ឡានដឹកទំនិញ និង កុងទន័រ

## ប្រព័ន្ធអនុវត្តច្បាប់ថ្មីនឹងផ្ញើរសំបុត្រពិន័យចំនួន ៧៥ ដុល្លារទៅតាមប្រអប់សំបុត្រដល់ម្ចាស់យានយន្តដែលគ្មានការអនុញ្ញាត សម្រាប់រាល់ការធ្វើដំណើរខុស

## ច្បាប់

westseattlebridge@seattle.gov ២០៦-៤០០-៧៥១១

ស៊ីអាថូ(ថ្ងៃទី ២៩ខែធ្នូ ឆ្នាំ២០២០)
ជាមួយស្ពានអាកាសស៊ីអាថូខាងលិចដែលត្រូវបានបិទសំរាប់សុវត្ថិភាពសាធារណៈ
ស្ពានទាបស៊ីអាថូខាងលិច(ត្រូវបានគេហៅថា ស្ពកខេនអេសស្ទឺប្រ៊ីច)
បានក្លាយជាផ្លូវសំខាន់បំផុតសម្រាប់រថយន្តសង្គ្រោះបន្ទាន់
រថយន្តក្រុងនិងឡានដឹកទំនិញធុនធ្ងន់ដើម្បីចូលនិងចេញពីទីក្រុង ស៊ីអាថូខាងលិច ។

ដើម្បីរក្សាផ្លូវសំខាន់នេះឱ្យអត់កកស្ទះឬក៏ធ្វើឲ្យផ្លូវទំនេរសម្រាប់ការធ្វើដំណើរសំខាន់ៗ
យានយន្តដទៃទៀតមិនអាចបើកបរលើស្ពានទាបចន្លោះពីម៉ោង ៥ព្រឹក ទៅ ៩ល្ងាច។
ចាប់ពីថ្ងៃទី១១ខែមករាឆ្នាំ២០២១ នាយកដ្ឋានដឹកជញ្ជូនស៊ីអាថូ  អេសឌីអូធី(SDOT)
និងចាប់ផ្តើមបើកធ្វើកាចាប់រូបថតតាមរយៈប្រព័ន្ធស្វ័យប្រវត្តិដែលនិងចេញសំបុត្រពិន័យ៧៥
ដុល្លារដល់ម្ចាស់យានយន្តដែលគ្មានការអនុញ្ញាតដែលបានឆ្លងកាត់ស្ពានទាបក្នុងទិសដៅទាំងសង
ខាង។

ច្បាប់ដែលចែងពីយានយន្តអាចប្រើស្ពានទាបមិនផ្លាស់ប្តូរនោះទេះ

- យានយន្តដែល ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ស្ពានទាបចាប់ពីម៉ោង ៥ ព្រឹកដល់ ៩ ល្ងាច គឺជារថយន្តសង្គ្រោះបន្ទាន់ ឡានក្រុង យានយន្តដឹកនាយោជិក ឡានដោយសាគ្នា កុងទន័រនិង យានយន្តដែលមានការអនុញ្ញាតជាមុន។
- ប្រជាជនដែលជិះស្គូតឺ កង់ រថយន្តក្រុង រឺក៏ថ្មើរជើងអាចឆ្លងកាត់តាមស្ពានទាបគ្រប់ពេល។
- សំរាប់យានយន្តទាំងអស់(រួមបញ្ចូលទាំង រថយន្តផ្ទាល់ខ្លួន ម៉ូតូ ឡានតាក់ស៊ី និងការហៅជិះរថយន្តតាមកម្មវិធីដូចជា អ៊ីបប៊ីនិងលីវ មិនអាចអនុញ្ញាតឲ្យជិះចូលស្ពានទាបចាប់ពីម៉ោង៥ព្រឹក ដល់ ម៉ោង៩យប់ និងត្រូវផ្ញើសំបុត្រពិន័យ៧៥ ដុល្លារ។
- អ្នករាល់គ្នាអាចបើកបរលើស្ពានទាបនៅពេលយប់ពីម៉ោង ៩ យប់ ដល់ម៉ោង ៥ ព្រឹកនិងមិនត្រូវបានគេផ្ញើសំបុត្រពិន័យទេក្នុងអំឡុងពេលទាំងអស់នេះ។

ការរឹតត្បិតការជិះចូលនៅលើស្ពានទាបគឺចាំបាច់ដើម្បីរក្សាផ្លូវទំនេរសម្រាប់យានយន្តសំខាន់ៗដែល
ត្រូវបានអនុញ្ញាតហើយជាពិសេសសម្រាប់រថយន្តសង្គ្រោះបន្ទាន់ដើម្បីទៅដល់មន្ទីរពេទ្យ។
ស្ពានទាបគឺជាផ្លូវតែមួយប៉ុណ្ណោះក្នុងទិសដៅទាំងសងខាងហើយមិនមានកន្លែងសម្រាប់រថយន្តទាំ
ងអស់ដែលធ្លាប់ធ្វើដំណើរនៅលើស្ពានខ្ពស់ផ្លូវ ទី៧ទេ ។
ប្រសិនបើគ្មានការរឹតត្បិតទាំងអស់នេះទេវានឹងបង្កើតការកកស្ទះចរាចរណ៍ពីម្ខាងទៅម្ខាង
និងការរងចាំយូរ។

ផ្លូវជំនួសសំរាប់អ្នកធ្វើដំណើរដែលមិនអាចបើកបរលើផ្លូវស្ពានទាបបាន
រួមមានទាំងផ្លូវទី១ស្ពានខាងត្បូង (ឬក៏សោសផាកប្រ៊ីច)។

អេសឌីអូធី(SDOT)
គឺនូវតែបន្តជួយប្រជាជនឲ្យអាចធ្វើដំណើរឆ្លងកាត់ទៅមកពីទីក្រុងស៊ីអាថូខាងលិច។តាមរយៈ
ក្របខ័ណ្ឌគំរោងរបស់រីខនិកវេស ស៊ីអាថូ (Reconnect West Seattle)

យើងកំពុងធ្វើការជាមួយសហគមន៍ដែលនៅក្បែរៗ
ដើម្បីផ្ដល់អាទិភាពដល់គម្រោងនានាដែលនឹងកាត់បន្ថយផលប៉ះពាល់នៃការបង្កើនចរាចរណ៍ផ្លូវជំ
នួសផ្លូវបិត ផ្ដល់អាទិភាពដល់ការតភ្ជាប់ឆ្លងកាត់ទៅនិងមកពី ទីក្រុងស៊ីអាថូខាងលិច
កសាងគំរោងកង់ថ្មី និងធ្វើការបង្កើតនិងកែលំអផ្លូវជំនួសផ្លូវបិត ។

ប្រជាជនអាចស្វែងរកជំនួយផងដែលតាមរយៈការស្រាវជ្រាវជម្រើសធ្វើដំណើររបស់ពួកគេនៅក្នុងគេហទំព័រ [West Seattle and Duwamish Valley Travel Options portal.]

ប្រព័ន្ធពង្រឹងតាមចាប់រូបភាពនឹងដំណើរការដូចជាកាមេរ៉ាចរាចរណ៍នៅផ្នែកផ្សេងទៀតនៃទីក្រុង
ស៊ីអាថូ
ដែលចេញសំបុត្រសម្រាប់ការរំលោភបំពានភ្លើងពណ៌ក្រហមឬល្បឿនលឿនក្នុងតំបន់សុវត្ថិភាពសាលារៀន។

ប្រព័ន្ធនឹងថតយកស្លាកលេខរថយន្តនៅពេលពួកគេឆ្លងកាត់ស្ពានទាប។
វានឹងត្រូវបានប្រៀបធៀបទៅនឹងបញ្ជីនៃស្លាកលេខដែលបានអនុញ្ញាតហើយប្រសិនបើយានយន្តមិនត្រូវបានអនុញ្ញាតឱ្យធ្វើដំណើរនៅលើស្ពានទាបនោះសំបុត្រពិន័យ ៧៥
ដុល្លារនិងត្រូវបានផ្ញើទៅម្ចាស់យានយន្តតាមរយះអាស័យដ្ឋានបានចុះ នៅក្នុងឈ្មោះយានយន្ត។

ប្រព័ន្ធពង្រឹងតាមចាប់រូបភាពមានអត្ថប្រយោជន៍ច្រើននិងមានប្រសិទ្ធិភាពខ្ពស់។
នេះមានន័យថានិងមានប៉ូលិសតិចជាងមុនប្រចាំការធ្វើការ
និងការធ្វើចរាចរណ៍ដោយផ្ទាល់នៅកន្លែង
ដូច្នេះប៉ូលីសអាចផ្តោតលើតម្រូវការសុវត្ថិភាពសាធារណៈដទៃទៀត។
វាក៏ធ្វើឱ្យការអនុវត្តច្បាប់មានលក្ខណៈផ្លូវការនិងគោលបំណងដោយលុបបំបាត់ការទស្សន៍ទាយដែលគ្រាន់តែមើលឃើញហើយគិតថាតើអ្នកណាអនុញ្ញាតឬមិនត្រូវបានអនុញ្ញាតឱ្យប្រើស្ពានទាប។

អ្វីដែលសំខាន់បំផុតនោះប្រព័ន្ធនឹងជួយរារាំងអ្នកឆបោកពីការប្រើប្រាស់ស្ពានដើម្បីឱ្យរថយន្តស
ង្គ្រោះបន្ទាន់
កុងទន័រនិងរថយន្តដឹកទំនិញឆ្លងកាត់អាចធ្វើដំណើរប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព។

ដើម្បីការពារភាពឯកជនកាមេរ៉ានឹងថតតែស្លាកលេខរថយន្តហើយមិនមែនមនុស្សនៅខាងក្នុងឡានទេ។
រូបថតទាំងនេះត្រូវបានគេប្រើប្រាស់សម្រាប់អនុវត្តការរឹតត្បិតលើស្ពានទាបហើយមិនមានបំណងសម្រាប់ការអនុវត្តច្បាប់ផ្សេងទៀតឡើយ។

រថយន្តសង្គ្រោះបន្ទាន់
កុងទន័រនិងរថយន្តដឹកទំនិញឆ្លងកាត់ត្រូវបានអនុម័តដោយស្វ័យប្រវត្តិដើម្បីប្រើស្ពានទាបហើយនឹងមិនទទួលបានសំបុត្រដើម្បីផាកពិន័យទេ។

ចំនួនអ្នកធ្វើដំណើរតាមសមុទ្រដែលបានកំណត់ទុក រដ្ឋាភិបាលនិងយានយន្តដែលដឹករកស៊ី
របស់ទីក្រុងស៊ីអាថូខាងលិច ដែលមានមុខងារ
ក្នុងការងារបន្ទាន់នៅក្បែរនោះត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ស្ពាននេះ។

អេសឌីអូធី(SDOT)
បានធ្វើការជាមួយអង្គការទាំងនេះដើម្បីបញ្ចូលស្លាកលេខរបស់ពួកគេទៅក្នុងប្រព័ន្ធ។
ប្រសិនបើអ្នកជឿជាក់ថាអ្នកមានសិទ្ធិទទួលបានការអនុញ្ញាតជាមុនដោយផ្អែកលើការពិពណ៌នាខាងលើ សូមអ៊ីមែល westseattlebridge@seattle.gov ឬហៅទៅ ២០៦-៤០០-៧៥១១

អេសឌីអូធី(SDOT) និងធ្វើការតាមដានជាមួយស្ពានទាបចរាចរណ៏នៅក្នុងដើមឆ្នាំ២០២១
បន្ទាប់ពីប្រព័ន្ធតាមដានត្រូវបានអនុវត្ត។

ប្រសិនបើទិន្នន័យរបស់ចរាចរណ៍និងបង្ហាញពួកយើងនូវកន្លែងដែលសល់អាចឲ្យធ្វើដំណើរបាន យើងនិងធ្វើការជាមួយ
ក្រុមការងារសហគមន៍ស្ពានស៊ីអាថូខាងលិចដើម្បីរកវិធីសាស្រ្តមានតុល្យភាពសម្រាប់ការចូលធ្វើដំណើរនៅលើស្ពានទាប។

*****

## សំនួរដែលគេសួរជាញឹកញាប់អំពីការអនុវត្តច្បាប់ស្តីពីការតាមចាប់រូបភាពនៅស្ពានទាបនៅភាគខាងលិចនៃទីក្រុងស៊ីអាថូ

### តើវាចំណាយពេលប៉ុន្មានដើម្បីទទួលបាននូវការជូនដំណឹងអំពីការជិះចូលខុសច្បាប់នេះ?

អ្នកចុះបញ្ជីឈ្មោះរថយន្តដែលមិនបានអនុញ្ញាតឲ្យជិះចូលនិងត្រូវបានជូនដំណឹងអំពីការជិះចូលខុសច្បាប់តាមរយៈអាស័យដ្ឋានប្រអប់សំបុត្រក្នុងរយៈពេល ១៤ថ្ងៃ។
ការផាកពិន័យនិងត្រូវបានធ្វើឡើងសំរាប់ផ្លូវទាំងសងខាងរបស់ស្ពាន។
ប្រសិនបើការរំលោភបំពានបានកើតឡើងដោយការជិះរថយន្តជួលចូលនៅលើផ្លូវ
ពេលវេលាជូនដំណឹងនឹងមានរយៈពេលយូរជាងនេះ៕

ក្រុមហ៊ុនរថយន្តជួលមានឱកាសដើម្បីកំណត់អត្តសញ្ញាណអ្នកបើករថយន្តនិងបញ្ជូនព័ត៌មានដូច្នេះ ការជូនដំណឹង អំពីការជិះចូលខុសច្បាប់ត្រូវបានផ្ញើទៅអ្នកជួលយានយន្ត។

តុលាការក្រុងស៊ីអាថូនិងផ្តល់ជម្រើសសម្រាប់សេវាកម្មសហគមន៍ជម្រើសឱ្យការបង់ថ្លៃសេវានិងផែនការ បង់ការប្រាក់សូន្យ
ដើម្បីកាត់បន្ថយការលំបាកផ្នែកហិរញ្ញវត្ថុដល់បុគ្គលនិមួយៗដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។
ប្រសិនបើអ្នកទទួលបានការជូនដំណឹងអំពីការជិះចូលខុសច្បាប់អ្នកមានពេល ១៨ ថ្ងៃដើម្បីបង់វា។

### តើខ្ញុំបង់ប្រាក់ពិន័យដោយរបៀបណា?

បើសិនជាអ្នកទទួលបានលិខិតអំពីការជិះចូលខុសច្បាប់
អ្នកអាចបង់ប្រាក់ពិន័យក្នុងរយៈពេល១៨ថ្ងៃ។ អ្នកមានជម្រើសបង់ប្រាក់ចំនួនបី៖

1. អ្នកអាចផ្ញើមូលប្បទានប័ត្រ(សែក)ឬ ប្រាក់បញ្ញើទិញ នៅក្នុងមូលនិធិសហរដ្ឋអាមេរិក បង់ជូនតុលាការក្រុងស៊ីអាថូ សម្រាប់ចំនួនទឹកប្រាក់ដែលបានបង្ហាញនៅខាងមុខ នៅថ្ងៃបរិច្ឆេទឬ មុនកាលបរិច្ឆេទកំណត់។
សូមដាក់សំបុត្រដែលភ្ជាប់ជាមួយការទូទាត់ការបង់ប្រាក់របស់អ្នក។
សរសេរលេខជូនដំណឹងរបស់អ្នក # និងស្លាកលេខរបស់អ្នក # លើមូលប្បទានប័ត្រ(សែក)ឬ ប្រាក់បញ្ញើទិញរបស់អ្នក ។ សូមមេត្តាកុំផ្ញើសាច់ប្រាក់សុទ្ធ។

2. បង់ប្រាក់តាមអ៊ិនធេណេតនៅថ្ងៃបរិច្ឆេទឬមុនកាលបរិច្ឆេទកំណត់តាមរយៈ
www.seattle.gov/courts/ticketinformation.htm
ឬតាមរយៈប្រព័ន្ធបង់ប្រាក់ស្វ័យប្រវត្តិរបស់យើងដែលអាចចូលប្រើបានពីទូរស័ព្ទណាដែលអាចភ្ជាប់តាមលេខ(២០៦)២៣៣-៧០០០ ។

3. បង់ប្រាក់ដោយផ្ទាល់នៅថ្ងៃបរិច្ឆេទឬមុនកាលបរិច្ឆេទកំណត់គឺថ្ងៃច័ន្ទដល់ថ្ងៃសុក្រវេលាម៉ោង ៨:០០ព្រឹក ដល់៥:០០ល្ងាចនៅ ការិយាល័យទូទាត់ប្រាក់សំណងរបស់តុលាការនៅជាន់ទី ១ នៃអាគារតុលាការក្រុងស៊ីអាថូ ៦០០ ផ្លូវហ្វិបអាវិន្យូ ទីក្រុងស៊ីអាថូ, រដ្ឋវ៉ាស៊ីងតោន។
ប្រអប់បង់ប្រាក់គឺស្ថិតនៅទុលមុខអាគារតុលាការក្រុងស៊ីអាថូសំរាប់អ្នកដែលបង់ក្រោយម៉ោងធ្វើការសំរាប់ភាពងាយស្រួល។

### តើខ្ញុំតវ៉ាការផាកពិន័យដោយរបៀបណា?

សូមប្រើសំបុត្រដាក់ភ្ជាប់ជាមួយសំបុត្រផាកពិន័យរបស់អ្នកដើម្បីស្នើរសុំទៅកាន់សវនាការសំរាលទោស ឬសវនាការជំទាស់។ ដើម្បីដាក់ពាក្យការប្រកាស់មិនទទួលខុសត្រូវ សូមធ្វើតាមការនែនាំរបស់ការផាកពិន័យដូចខាងក្រោម ៖

- ការកោះហៅដើម្បីបកស្រាយ អំពីស្ថានភាព :  តាមរយៈការស្នើរសុំទៅកាន់សវនាការសំរាលទោស អ្នកនិងត្រូវបានចាត់ទុកថាទទួលកំហុសនៃការជិះចូលបំពាន។ អ្នកមិនអាចកោះហៅសាក្សីក្នុងសវនាការនេះបានទេ។ អ្នកអាចស្នើសុំសវនាការសំរាលទោសប្រសិនជាអ្នកទទួលស្គាល់កំហុសនៃការជិះចូលបំពាន ប៉ុន្តែបើយោងតាមស្ថានការវាអាចឲ្យតុលាការកាត់បន្ថយឬក៏លើកលែងការផាកពិន័យនេះ។

- ការតវ៉ាក្នុងសវនាការនៃការជិះចូលបំពាន : នៅពេលការតវ៉ាក្នុងសវនាការ អញ្ញាធរទីក្រុងត្រូវផ្តល់នូវបុព្វហេតុភស្តុតាងនៃការជិះចូលបំពានដែលបានកើតឡើង។ អ្នកអាចកោះហៅសាក្សី រួមបញ្ចូលទាំងប៉ូលិសដែលចេញសំបុត្រពិន័យនេះ។ ប្រសិនបើអ្នកស្នើសុំសវនាការតវ៉ាតុលាការនិងណាត់ជួបមុននិងឡើងសវនាការទុកជាមុន ដែលអ្នកអាចបដិសេធដោយប្រើឯកសារភ្ជាប់ជាមួយទៅនឹងសេចក្តីជូនដំណឹងអំពីសវនាការ ដែលតុលាការនិងផ្ញើរឲ្យអ្នកទុកជាមុន។

- ការដាក់ឯកសារប្រកាស់មិនទទួលខុសត្រូវ: ប្រសិនបើឡានរបស់អ្នកត្រូវបានចោរលួច ឬអ្នកលក់ឡានមុននិងថ្ងៃជិះបំពាន ឬក៏ម្យ៉ាងទៀតវាមិនស្ថិតក្នុងការគ្រប់គ្រងរបស់អ្នក មិននូវក្រោមកម្មសិទ្ធរបស់អ្នកឬក៏មិនមែននៅក្រោមការគ្រប់គ្រងនៅពេលមានការរំលោភបំពានកើតឡើង អ្នកអាចដាក់ពាក្យស្តីពីការថ្លែងការណ៍ពាក្យសម្បថ ដើម្បីតវ៉ាតុលាការឲ្យបដិសេធការសន្មត់ ត្រូវបានសំរេចក្នុង អេសអឹមស៊ី(SMC) ១១.៣១.០៩០ ដែលបានបញ្ជាក់ថាអ្នកបានបើកបរក្នុងពេលជិះបំពាន។

**តើខ្ញុំអាចសុំមើលភស្តុតាងពីការជិះខុសច្បាប់ឆ្លងកាត់ស្ពានទាបបានទេ?**

អ្នកអាចចូលមើលរូបថតនិងវីដេអូតាមអនឡាញក្នុងគេហះទំព័រ www.ViolationInfo.com. អ្នកត្រូវតែប្រើលេខជូនដំណឹង # និង លេខកូដដែលអាចរកឃើញលើសេចក្តីជូនដំណឹងដើម្បីចូលមើល។

មនុស្សដែលមិនអាចចូលមើលលើកុំព្យូទ័របានតែអាចចូល មើល បណ្ណាល័យសាធារណះរបស់ស៊ីអាថ្លូគ្រប់សាខា ឬនៅតុលាការក្រុង ៦០០ផ្លូវហ្វិបអាវេនន្ទូ ដើម្បីចូលមើលភស្តុតាងរូបថតនិងវីដេអូ។

**តើមានអ្វីនិងកើតឡើងចំពោះប័ណ្ណបើកបរ ឬធានារ៉ាប់រងរបស់ខ្ញុំបើខ្ញុំបង់ការពិន័យ ឬក៏គេរកឃើញថាខ្ញុំមានទោស?**

ការតាមចាប់រូបថតរបស់អ្នកជិះចូលខុសច្បាប់វាត្រូវបានគេចាត់ទុកដូចជាការចតរថយន្តខុសច្បាប់ដែល។ វាគ្មានបញ្ហាដល់ប័ណ្ណបើកបរ របស់អ្នកទេ គ្មានការវាយតំលៃពិន្ទុទេ ហើយក៏គ្មានបញ្ហារប៉ះពាល់ដល់ធានារ៉ាប់រងរបស់អ្នកដែល។

**ខ្ញុំមានការព្រួយបារម្ភអំពីភាពឯកជនរបស់ខ្ញុំ។**
**តើមានអ្វីកើតឡើងបន្ទាប់ពីកាមេរ៉ាថតរូបរបស់រថយន្តខ្ញុំ?**
**តើអ្នកគ្រប់គ្នាអាចចូលមើលវីដេអូបានរឺ?**

ដើម្បីរក្សាភាពឯកជន កាមេរ៉ានិងថតតែស្លាកលេខរថយន្តប៉ុណ្ណោះ មិនមានថតមនុស្សនៅក្នុងរថយន្តនោះទេ។ រូបថតទាំងនេះត្រូវបានគេប្រើប្រាស់សម្រាប់អនុវត្តការរឹតត្បិតលើស្ពានទាបហើយមិនមានបំណងសម្រាប់ការអនុវត្តច្បាប់ផ្សេងទៀតឡើយ។

ប្រព័ន្ធនិងប្រៀបធៀបស្លាកលេខទាំងអស់ជាមួយទិន្នន័យរបស់អ្នកដែលត្រូវបានអនុញ្ញាតឲ្យប្រើប្រា
ស់ ដើម្បីឲ្យដឹងថារថយន្តនោះត្រូវបានអនុញ្ញាតឲ្យជិះចូលទេ។ នាយកដ្ឋានប៉ូលិស
ស៊ីអាថូនិងធ្វើការត្រួតពិនិត្យរូបភាពឡើងវិញ រាល់គ្រប់អ្នកដែលជិះចូលបំពាន
មុនពេកនិងចេញសំបុត្រពិន័យ។ រថយន្តដែលគ្មានការអនុញ្ញាតទាំងអស់ត្រូវតែបង់៧៥ដុល្លារ
សំរាប់រាល់ការជិះឆ្លងកាត់ស្ពានទាបខុសច្បាប់ម្តងៗ ។

បកប្រែដោយ : រ័ត្ន ឥន្ទ ហេមបឺច(Roth En Hamberg)